# ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
## អគ្គលេខាធិការដ្ឋាន

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយចីរភាព
## (២០១៩-២០២៣)

### ដើម្បីធានាតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌
### នៃព្រះរាជាណាចក្រកម្ពុជា

*រៀបចំដោយៈ នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ*

ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០១៨

# មាតិកា

I. **សមិទ្ធផលនៅក្នុងការអនុវត្ត ផ.យ.អ.ឌ. ២០១៤-២០១៨**.............................. ១

១. ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា.............................. ១

១.១. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា.............................. ១

១.២. ការអភិវឌ្ឍបៃតង.............................. ២

២. ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ.............................. ៤

៣. ការងារជីវៈចម្រុះ និងជីវសុវត្ថិភាព.............................. ៥

តារាងទី១៖ សូចនាករសំខាន់ៗ តាមវិស័យសម្រាប់ឆ្នាំ២០១៤-២០១៨.............................. ៨

II. **បញ្ហាប្រឈមនៅក្នុងការអនុវត្ត ផ.យ.អ.ឌ. ២០១៤-២០១៨**.............................. ១៣

១. វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការអភិវឌ្ឍបៃតង.............................. ១៣

១.១. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា.............................. ១៣

១.២. ការអភិវឌ្ឍបៃតង.............................. ១៣

២. ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ.............................. ១៣

៣. ការងារជីវៈចម្រុះ និងជីវសុវត្ថិភាព.............................. ១៤

III. **គោលនយោបាយអាទិភាពសម្រាប់ ២០១៩-២០២៣**.............................. ១៤

១. ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា.............................. ១៤

១.១. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា.............................. ១៤

១.២. ការអភិវឌ្ឍបៃតង.............................. ១៥

២. ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ.............................. ១៥

៣. ការងារជីវៈចម្រុះ និងជីវសុវត្ថិភាព.............................. ១៧

តារាង២៖ គោលនយោបាយអាទិភាពសម្រាប់ឆ្នាំ២០១៩-២០២៣.............................. ២០

តារាងទី៣៖ ចំណាយប៉ាន់ស្មានសម្រាប់អនុវត្តគម្រោងនិងកម្មវិធីសម្រាប់ឆ្នាំ២០១៩-២០២៣.... ២២

# I. សមិទ្ធផលនៅក្នុងការអនុវត្ត ផ.យ.អ.ច. ២០១៤-២០១៨

## ១. ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

### ១.១. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- បានចុះសិក្សាស្វែងយល់ និងប្រមូលព័ត៌មានស្តីពីប្រើប្រាស់បច្ចេកវិទ្យាបៃតងនៅតាមបណ្តាខេត្តមួយចំនួន និងប្រទេសនានា
- កំពុងអនុវត្តគម្រោងសាកល្បងលើការប្រើប្រាស់បច្ចេកវិទ្យាទោចក្រយានយន្តអគ្គិសនី និងផ្ទាំងសូឡាដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់
- បានលើកកម្ពស់ចំណេះដឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដល់សាធារណៈជន តាមរយៈការរៀបចំអត្ថបទខ្លីៗស្តីពីការប្រើប្រាស់ថាមពលនុយក្លេអ៊ែសម្រាប់បម្រើឱ្យគោលបំណងសន្តិភាពដោយបានចុះផ្សាយក្នុងទស្សនាវដ្តីក្រសួងបរិស្ថាន គាំងពិព័រណ៍ និងសិក្ខាសាលានានា
- បានរៀបចំ និងកំពុងបន្តអនុវត្តអនុស្សរណៈនៃការយោគយល់ជាមួយសាជីវកម្មថាមពលបរមាណូរដ្ឋនៃសហព័ន្ធរុស្ស៊ីចំនួន៣
- បានរៀបចំ និងកំពុងបន្តអនុវត្តអនុស្សរណៈនៃការយោគយល់ជាមួយជាមួយសាជីវកម្មថាមពលនុយក្លេអ៊ែរជាតិនៃសាធារណរដ្ឋប្រជាមានិតចិនលើកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ព្រមទាំងកំពុងជំរុញការបង្កើតមជ្ឈមណ្ឌលព័ត៌មាននុយក្លេអ៊ែរឱ្យបានឆាប់
- បានរៀបចំក្រុមការងារថ្នាក់ជាតិ និងក្រុមការងាររួមកម្ពុជា-រុស្ស៊ីសម្រាប់កិច្ចសហប្រតិបត្តិការ និងបានរៀបចំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិជាច្រើនលើកនិងកិច្ចប្រជុំក្រុមការងាររួមកម្ពុជា-រុស្ស៊ីចំនួន ០២លើក
- បានរៀបចំដំណើរទស្សនកិច្ចសិក្សាស្វែងយល់អំពីការប្រើប្រាស់បច្ចេកវិទ្យាថាមពលនុយក្លេអ៊ែរ និងចូលវេទិកាអាតូមិកអន្តរជាតិនៅសហព័ន្ធរុស្ស៊ី
- រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហព័ន្ធរុស្ស៊ីបានចុះកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៧ នៅទីក្រុងវីយែន ប្រទេសអូទ្រីស។
- កំពុងរៀបចំកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហព័ន្ធរុស្ស៊ីស្តីពីការសាងសង់មជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរនៅព្រះរាជាណាចក្រកម្ពុជា
- បានសម្របសម្រួលជ្រើសរើសនិស្សិតកម្ពុជាទៅបន្តការសិក្សាស្តីពីបច្ចេកវិទ្យានុយក្លេអ៊ែរនៅសហព័ន្ធរុស្ស៊ី ដោយទទួលបានអាហាររូបករណ៍នៅពេលកំពុងសិក្សា និងការអនុញ្ញាតផ្តល់ក្របខណ្ឌការងារដោយស្វ័យប្រវត្តិនៅពេលបញ្ចប់ការសិក្សាពីរាជរដ្ឋាភិបាលកម្ពុជាផងដែរ
- បានផ្តល់យោបល់លើឯកសារផែនការសកម្មភាពជាតិនានាដែលពាក់ព័ន្ធនឹងថាមពលនុយក្លេអ៊ែរ ក៏ដូចជាការរៀបចំក្របខណ្ឌកម្មវិធីការងារថ្នាក់ជាតិសម្រាប់ទីភ្នាក់ងារថាមពលអាតូមិក

អន្តរជាតិ ពិសេសបានផ្តល់អនុសាសន៍លើសំណើសុំពីបណ្តាក្រុមហ៊ុនមួយចំនួនទាក់ទងការកសាងរោងចក្រថាមពលនុយក្លេអ៊ែរនៅកម្ពុជាផងដែរ។

- កំពុងប្រមូលព័ត៌មានដើម្បីរៀបចំសេចក្តីព្រាងក្រមសីលធម៌សម្រាប់ការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងកម្មវិធីសិក្សាស្រាវជ្រាវដែលគាំទ្រដល់ការអភិវឌ្ឍដោយចីរភាពក្នុងគោលបំណងណែនាំឱ្យការសិក្សាស្រាវជ្រាវមានស្តង់ដារជាតិតែមួយ និងចំទិសដៅ។

## ១.២. ការអភិវឌ្ឍបៃតង

- បានរៀបចំទីក្រុងនិរន្តរភាព គោលនយោបាយតម្រង់ទិសអភិវឌ្ឍន៍បៃតង ថាមពលនិរន្តរភាព ការប្រើប្រាស់និងផលិតដោយចីរភាព ការរៀបចំដំឡើងបន្ទះថាមពលពន្លឺព្រះអាទិត្យ និងការងារពាក់ព័ន្ធមួយចំនួនទៀត
- បានបញ្ចប់ផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៦-២០២៥ ដោយមានការចូលរួមពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- បានជ្រើសរើសក្រុងចំនួន៧ រួមមាន ក្រុងបាវិត ក្រុងកំពង់ចាម ក្រុងសួង ក្រុងកែប ក្រុងព្រះសីហនុ ក្រុងសៀមរាប និងក្រុងបាត់ដំបងដើម្បីរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព គោលនយោបាយ និងគម្រោងវិនិយោគទីក្រុងបៃតង
- បានសិក្សាលទ្ធភាពមុនពេលអនុវត្តគម្រោងស្តីពីផែនការសកម្មភាពវិនិយោគសម្រាប់ប្រព្រឹត្តិកម្មសំណល់រាវនៅក្នុងតំបន់ជាយក្រុងនៃរាជធានីភ្នំពេញ
- ក្រសួងការបរទេសនៃសាធារណរដ្ឋកូរ៉េ និងវិទ្យាស្ថានមេគង្គបានអនុម័តគម្រោងសំណើស្តីពីគោលការណ៍ណែនាំ និងវិញ្ញាបនបត្រសម្រាប់អគារបៃតងនៅកម្ពុជា និងចាប់ផ្តើមអនុវត្តក្នុងខែកញ្ញា ឆ្នាំ២០១៨ តទៅ
- បានសម្របសម្រួលកម្មវិធីតម្រង់ទិសគោលនយោបាយ សម្រាប់អភិវឌ្ឍន៍បៃតងដោយបានកំណត់អនុសាសន៍គោលនយោបាយអាទិភាព សម្រាប់អភិវឌ្ឍន៍បៃតងសម្រាប់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣
- បានសម្របសម្រួលជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្នុងការដំឡើងបន្ទះថាមពលពន្លឺព្រះអាទិត្យនៅលើអគារមេតេកោតេជោ (ទីស្តីការក្រសួងបរិស្ថាន) ចំនួន ៦៦ kWp DC/៥0KWAC ប្រហែលស្មើនឹង ៨,៥% នៃថាមពលប្រើប្រាស់សរុប ដើម្បីជំនួសឱ្យការប្រើប្រាស់ថាមពលអគ្គិសនីទាំងមូលពីបណ្តាញជាតិក្នុងអគារក្រសួងបរិស្ថាន
- បានសិក្សាលទ្ធភាពនៃការអនុវត្តគម្រោងថាមពលពន្លឺព្រះអាទិត្យនៅខេត្តកែប និងខេត្តកំពត
- បានផ្តល់យោបល់ស្តីពីការអភិវឌ្ឍគម្រោងកសិដ្ឋានផលិតថាមពលពន្លឺព្រះអាទិត្យកម្លាំង ១០ MW របស់ក្រុមហ៊ុន Sunseap Asset Co. Ltd នៅក្រុងបាវិត ខេត្តស្វាយរៀង និងកម្លាំង ៣០០ MW នៅតំបន់សេដ្ឋកិច្ចពិសេសក្រុងបាវិត ខេត្តស្វាយរៀង របស់ក្រុមហ៊ុន Dragon King Sez Co. Ltd

- បានចុះអនុស្សរណៈនៃការយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការទូទៅ រវាងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ជាមួយនឹង ១) អង្គការ USAID និងអង្គការ Clean Power Asia លើការជំរុញការសិក្សា និងការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ២) ក្រុមហ៊ុន The Energy Laboratory Limited ស្តីពីកិច្ចសហប្រតិបត្តិការ និងជំរុញការបង្កើតថ្មីនៃថាមពលស្អាត
- បានពិគ្រោះយោបល់លើគម្រូគម្រោងនៃការជំរុញការប្រើប្រាស់ផ្ទាំងពន្លឺព្រះអាទិត្យដើម្បីទទួលបានសន្តិសុខថាមពល និងការអភិវឌ្ឍដោយចីរភាព
- បានចូលរួមកំណត់ការកាត់បន្ថយហានិភ័យនៃការវិនិយោគថាមពលកកើតឡើងវិញសម្រាប់រៀបចំគម្រោងស្នើសុំទៅកាន់មូលនិធិអាកាសធាតុបៃតង
- បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍បរិស្ថានចិន(EDC)និងមជ្ឈមណ្ឌលវិញ្ញាបនបត្របរិស្ថានចិន (CEC) លើផែនការសកម្មភាពនៃគម្រោងសាកល្បងស្តីពី ការកសាងសមត្ថភាពស្តីពីស្លាកសញ្ញាបរិស្ថានសម្រាប់កម្ពុជា
- បានចុះអនុស្សារណៈនៃការយោគយល់រវាងអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ជាមួយមជ្ឈមណ្ឌលនវានុវត្តន៍អេកូសម្រាប់ជំនួបសហគ្រាសធុនតូច និងមធ្យមអាស៊ី-អឺរ៉ុប (ASEM Eco-Innovation Center-ASEIC) ស្តីពីកិច្ចសហការសម្រាប់ការកសាងសមត្ថភាពនវានុវត្តន៍អេកូ និងការលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មដែលបញ្ចេញកាបូនទាប (Cooperation for ASEM Eco-Innovation Capacity Building Project and the Promotion of Low-Carbon Industrial Development)
- បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលចំនួន០២ជាមួយASEM Eco-Innovation Center -ASEIC ៖ ស្តីពីបង្កើតមូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធផ្តល់ស្លាកសញ្ញាអេកូនៅកម្ពុជា (Forming the Bedrock for an Eco-labeling System in Cambodia) និងការកសាងសមត្ថភាពនវានុវត្តន៍អេកូសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា(Capacity Building on Eco-Labeling for Small and Medium Enterprises in Cambodia)
- បានរៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពស្តីពីការចែករំលែកបទពិសោធន៍ និងភាពជោគជ័យនៃការអភិវឌ្ឍសេដ្ឋកិច្ចបៃតង
- បាននសហការជាមួយអង្គការ WWF ប្រចាំកម្ពុជា ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពី "ការអភិវឌ្ឍបៃតងៈដ្យាក្រាមវដ្តទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋា (តំណាងកសិករ)" ជាមួយប្រជាកសិករ និងស្ថាប័ន/អង្គភាពពាក់ព័ន្ធ
- បានរៀបចំកិច្ចប្រជុំពិភាក្សាបច្ចេកទេស "ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ"
- បានធ្វើមូលដ្ឋានទូបនីយកម្មសូចនាករពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព និងសេដ្ឋកិច្ចបៃតង
- បានរៀបចំសេចក្តីព្រាងសេចក្តីសម្រេចបង្កើតក្រុមការងារបច្ចេកទេសចំនួនបី គឺ៖ (១) ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព (២) ក្រុមការងារបច្ចេកទេសថាមពលនិរន្តរភាព និង (៣) ក្រុមការងារបច្ចេកទេសការប្រើប្រាស់និងការផលិតដោយនិរន្តរភាព។

## ២. ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

ការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (ផ.យ.ប.អ.ក.) ២០១៤-២០២៣ ក្របខណ្ឌហិរញ្ញប្បទាន ផែនការជាតិបន្សាំ និងផែនការអនុវត្តកម្ពុជា និងផែនការស្តីពីការចូលរួមចំណែករបស់រដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (Nationally Determined Contribution: NDC) ដែលរួមទាំងការអនុវត្តវិធានការដាក់លាក់សម្រាប់បន្សាំការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់គឺជាអាទិភាពចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់អាណត្តិទី៥ និងអាណត្តិបន្ត។ ផែនការ ផ.យ.ប.អ.ក. បាន និងកំពុងអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធដោយទទួលបានសមិទ្ធផលគួរឱ្យកត់សម្គាល់សម្រាប់រយៈពេលមធ្យម(២០១៤-២០១៨)។

សមិទ្ធផលសម្រេចបានពីការអនុវត្ត ផ.យ.អ.ជ. សម្រាប់អាណត្តិទី៥ មានជាអាទិ៍៖

### ក. ការរៀបចំស្ថាប័ន ផែនការ និងគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ

រចនាសម្ព័ន្ធថ្មីនៃនាយកដ្ឋានប្រែប្រួលអាកាសធាតុត្រូវបានដាក់នៅក្រោម អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ រចនាសម្ព័ន្ធថ្មីនេះត្រូវបានរៀបចំឡើងនៅខែមីនា ឆ្នាំ២០១៥ ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តវិធានការជាតិឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត។ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុដែលមានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៧។

ដោយអនុលោមតាមសេចក្តីសម្រេចរបស់សន្និសីទបណ្តាភាគីនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកទី២១ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ២០១៦។ នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាពបានជំរុញការអនុវត្តគម្រោង និងកម្មវិធីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដូចជាកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើ (REDD+) គម្រោងយន្តការផ្តល់ឥណទានកាបូនរួមគ្នា (JCM) ចំនួន ៤ និងគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM) ចំនួន ១២ ដែលបាននិងកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ខ. ក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុកម្ពុជា

ក្របខណ្ឌនេះត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៤ ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើបច្ចុប្បន្នភាពលើការចំណាយ ការប៉ាន់ស្មាន ការវិភាគផលចំណេញ និងការគ្រប់គ្រងថវិការបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសអាធាតុ។ ការសិក្សាស្តីពីការពិនិត្យឡើងវិញនូវការចំណាយសាធារណៈលើកិច្ចការអាកាសធាតុ (CPER) ត្រូវបានរៀបចំជាប្រចាំចាប់តាំងពីឆ្នាំ២០០៩-២០១៤ ដែលការសិក្សានេះបានបង្ហាញពីកំណើននៃការចំណាយថវិការបស់រាជរដ្ឋាភិបាលលើការប្រែប្រួលអាកាសធាតុធៀបនឹងផ.ស.សពី១% នៅឆ្នាំ២០១៣ ដល់ ១,៣% នៅឆ្នាំ២០១៤(សូនោគរ NSDP ៣.៤)។ លទ្ធផលនេះឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដើម្បីកៀរគរហិរញ្ញប្បទានអាកាសធាតុ

សម្រាប់ការអនុវត្ត ផ.យ.ប.អ.ក.។ លើសពីនេះ គ្រឹះស្ថានមួយចំនួនកំពុងពង្រឹងប្រព័ន្ធ និងប្រតិបត្តិការរបស់ខ្លួនដែលជាផ្នែកមួយ នៃសកម្មភាពដែលផ្តោតសម្រាប់រយៈពេលមធ្យម (ឆ្នាំ២០១៤-២០១៨) ដើម្បីមានលទ្ធភាពប្រើប្រាស់មូលនិធិអាកាសធាតុដោយផ្ទាល់ ដូចជា មូលនិធិបន្សាំ ឬ មូលនិធិអាកាសធាតុបៃតង ក្នុងនោះយ៉ាងហោចណាស់មានស្ថាប័នចំនួនពីរ (ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) ដែលបង្ហាញពីវឌ្ឍនភាពជាច្រើនក្នុងដំណើរការនៃការស្វែងរកការទទួលស្គាល់ជាផ្លូវការនេះ។

គម្រោងបន្សាំថ្នាក់សហគមន៍ចំនួន២០ក្នុងវិស័យពាក់ព័ន្ធចំនួន៨ បាននឹងកំពុងអនុវត្តដែលជាលទ្ធផលគ្រួសារនៃសហគមន៍គោលដៅលើសពី៧០%បានកាត់បន្ថយភាពងាយរងគ្រោះ មន្ត្រីជាង ២.២០០ នាក់ បានទទួលការបណ្តុះបណ្តាល សមាជិកសហគមន៍ជាង៤០០០០នាក់ បានទទួលការបណ្តុះបណ្តាលលើបច្ចេកវិទ្យាបន្សាំ ជិត២០០០០គ្រួសារបានទទួលប្រយោជន៍ផ្ទាល់ពីបច្ចេកវិទ្យាបន្សាំ។

**គ.ក្របខណ្ឌជាតិតាមដានត្រួតពិនិត្យ និងវាយតម្លៃ (M&E) ការប្រែប្រួលអាកាសធាតុ**

បច្ចុប្បន្ន ការរៀបចំស្ថាប័ន និងប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ M&E ត្រូវបានពង្រឹង។ ក្របខណ្ឌជាតិតាមដានត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុ និងក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុតាមវិស័យ សម្រាប់ក្រសួងសាធារណការ និងដឹកជញ្ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសុខាភិបាលត្រូវបានរៀបចំឡើងនៅឆ្នាំ២០១៦។

**ឃ. ការគ្រប់គ្រងចំណេះដឹង និងព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ**

ក្របខណ្ឌជាតិគ្រប់គ្រងចំណេះដឹង សម្រាប់ការប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតតាមរយៈគេហទំព័រ www.camclimate.org.kh។ សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ ឯកសារអប់រំស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ប័ណ្ណព័ត៌មាន វីដេអូ និងព្រឹត្តិបត្រព័ត៌មានត្រូវបានរៀបចំ និងបោះពុម្ពផ្សព្វផ្សាយ។

## ៣. ការងារជីវៈចម្រុះ និងជីវសុវត្ថិភាព

ការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះឆ្នាំ២០១៦ ដែលផ្តោតលើប្រធានបទចំនួន ២៤ ក្នុងនោះមានគោលដៅជាតិចំនួន ២០ គោលដៅយុទ្ធសាស្ត្រចំនួន ៧៨ និងសកម្មភាពសំខាន់ៗចំនួន៤៩៨ គឺជាឯកសារអាទិភាពគន្លឹះរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការតាំងចិត្តអនុវត្តកិច្ចការពារ និងអភិរក្សជីវៈចម្រុះក្នុងអាណត្តិទី៦ នេះ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះនេះបាន និងកំពុងអនុវត្តបន្តជាបណ្តើរៗដោយមានសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងវិស័យពាក់ព័ន្ធនានា។

**សមិទ្ធផលសម្រេចបានសំខាន់ៗក្នុងការអនុវត្ត ផ.យ.អ.ជ. អាណត្តិទី៥ មានជាអាទិ៍**

ការពង្រឹងរចនាសម្ព័ន្ធ និងស្ថាប័នគ្រប់គ្រងជីវៈចម្រុះ ដោយបង្កើតនាយកដ្ឋានជីវៈចម្រុះ និងក្រុមការងារបច្ចេកទេសជីវៈចម្រុះនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពដែលមានតួនាទី និងភារកិច្ចរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និង

យន្តការដោយឡែក និងជាអង្គភាពបង្គោល ព្រមទាំងដឹកនាំអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ។ ការបង្កើត និងកែសម្រួលអង្គភាពបច្ចេកទេសពាក់ព័ន្ធនឹងការងារជីវៈចម្រុះ គឺជាលទ្ធផលនៃដំណើរការកែទម្រង់ស្ថាប័នក្នុងពេលបច្ចុប្បន្នដែលដឹកនាំដោយរាជរដ្ឋាភិបាលកម្ពុជា។

រចនាសម្ព័ន្ធថ្មីនេះមានតួនាទីអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ពិធីសារនៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងជីវៈចម្រុះ និងជីវសុវត្ថិភាព។ ក្រុមការងារបច្ចេកទេសជីវៈចម្រុះ មានសមាជិកមកពីក្រសួង ស្ថាប័នរដ្ឋ និងអាជ្ញាធរដែនដីដែលមានបេសកកម្ម និងតួនាទីពាក់ព័ន្ធទៅនឹងកិច្ចការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ធនធានជីវៈចម្រុះ និងជីវសុវត្ថិភាពឱ្យកាន់តែមានភាពរឹងមាំ និងបំពេញបន្ថែមគ្នាក្នុងវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ដូចជា កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ ពាណិជ្ជកម្ម សុខាភិបាល អប់រំ។ល។ ជាមួយនឹងកិច្ចប្រឹងប្រែងកសាង និងពង្រឹងសមត្ថភាពរបស់ស្ថាប័នឱ្យដំណើរការទៅជាប្រចាំ។

ការអនុវត្តអនុសញ្ញាអន្តរជាតិ និងពិធីសារពាក់ព័ន្ធនានា និងការបញ្ជ្រាបជីវៈចម្រុះ បាននិងកំពុងប្រតិបត្តិផ្អែកលើយុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានច្បាប់ដែលបានរៀបចំរួច និងបំពេញបន្ថែម ព្រមទាំងរៀបចំកែសម្រួលរចនាសម្ព័ន្ធស្ថាប័នប្រតិបត្តិ និងយន្តការថ្មីៗមួយចំនួន សំដៅធានាប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានពន្ធុ ជីវសុវត្ថិភាព និងមុខងារសេវាកម្មប្រព័ន្ធអេកូឡូស៊ីដើម្បីគាំទ្រ និងគាំពារដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឱ្យមាននិរន្តរភាព។ ការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក៏បានចាប់ផ្តើមអនុវត្តនៅឆ្នាំបន្តបន្ទាប់ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ។

បច្ចុប្បន្ន តំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា រួមមាន តំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះគ្របដណ្តប់លើផ្ទៃដី(ដីគោក និងសមុទ្រ) **ប្រមាណជា៤១%** នៃផ្ទៃប្រទេសស្មើនឹងជាង**៧លានហិកតា** គឺខ្ពស់ជាងគោលដៅអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះដែលបានអំពាវនាវប្រទេសហត្ថលេខីត្រូវកំណត់បង្កើតតំបន់ការពារធម្មជាតិឱ្យបានប្រមាណ១៧%នៃផ្ទៃប្រទេស និងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះបានកំណត់ត្រឹមតែ**៣លានហិកតា**ជាផ្ទៃដីការពារ។

ទោះជាយ៉ាងណាក្តី ក៏ប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជានាពេលបច្ចុប្បន្ន កំពុងទទួលរងសម្ពាធ និងក្តីបារម្ភយ៉ាងខ្លាំងអំពីប្រសិទ្ធភាពនៃការការពារជីវៈចម្រុះ តែបានផ្តល់ឱកាសសម្រាប់ការចិញ្ចឹមជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានប្រកបដោយចីរភាព។ ដើម្បីធានាឱ្យការគ្រប់គ្រងបានល្អ និងមានប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងបរិស្ថានជាសេនាធិការបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រមួយចំនួនពាក់ព័ន្ធនឹងការអភិរក្សជីវៈចម្រុះរួមមាន ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ(២០១៧-២០៣១) ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងប្រភេទរាតត្បាត ជាដើម។ ផែនការទាំងនេះបានឆ្លុះបញ្ចាំងពីឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការថែរក្សា និងការពារជីវៈចម្រុះ។ ក្រសួងបរិស្ថានសហការជាមួយអាជ្ញាធរដែនដីបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលបានទទួលសិទ្ធិពេញលេញ និងស្របច្បាប់

ពីក្រសួងបរិស្ថានក្នុងការប្រើប្រាស់ធនធានធម្មជាតិដែលជាផ្នែកមួយនៃតំបន់ការពារធម្មជាតិបាន ចំនួន ១៥៣ គិតត្រឹមឆ្នាំ២០១៨ លើផ្ទៃដី២៥៥,០៧៦.០០ហិកតា។ របាយការណ៍ជាតិលើកទីមួយ ស្តីពីស្ថានភាពជីវចម្រុះ២០១៦ ត្រូវបានរៀបចំឡើងដោយក្រសួងបរិស្ថានក្នុងការឆ្លើយតបទៅនឹងការ អនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីជីវៈចម្រុះដោយផ្អែក លើការប្រមូល និងវាយតម្លៃបន្ថែមលើទិន្នន័យជីវៈចម្រុះដែលមានស្រាប់ តម្លៃជីវៈចម្រុះ ភាពសម្បូរនៃ ពន្ធុរុក្ខជាតិសត្វ ប្រភេទរុក្ខជាតិ ថនិកសត្វ ល្មូន សិប្បីសត្វ ត្រី បក្សាបក្សី និងសត្វឥតឆ្អឹងកង និងនានា ភាពនៃប្រព័ន្ធអេកូឡូស៊ី។ គណៈរដ្ឋមន្ត្រីបានសម្រេចអនុញ្ញាតឱ្យក្រសួងបរិស្ថាន និងអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើម្បីសិក្សា និងរៀបចំក្របខណ្ឌគោលនយោបាយស្តីពីការបង់ ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដោយអនុវត្តសាកល្បងនៅតំបន់ផ្ទៃរងទឹកភ្លៀងសំខាន់ៗមួយចំនួន។

លិខិតបទដ្ឋានច្បាប់ និងយន្តការចាំបាច់ពាក់ព័ន្ធនឹងកិច្ចការពារ និងប្រើប្រាស់ធនធានជីវៈ ចម្រុះ និងជីវសុវត្ថិភាពត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ដោយត្រូវកែសម្រួល និងរៀបចំបំពេញ បន្ថែមដើម្បីឆ្លើយតបទៅនឹងស្ថានការណ៍ចាំបាច់ និងកាលៈទេសៈនៃការវិវត្តលើការគ្រប់គ្រង និងប្រើ ប្រាស់ធនធានជីវៈចម្រុះ ធនធានពន្ធុ និងជីវសុវត្ថិភាព។ កម្ពុជាក៏បាន និងកំពុងកសាង និងពង្រឹង សមត្ថភាពស្ថាប័នរបស់ខ្លួនក្នុងការកៀរគរ និងប្រើប្រាស់ហិរញ្ញប្បទានជីវៈចម្រុះពីអន្តរជាតិដើម្បីរួម ចំណែកជាមួយរាជរដ្ឋាភិបាលក្នុងគោលដៅតែមួយ។ ដាក់ស្តែង ប្រព័ន្ធទិន្នន័យ និងព័ត៌មានជីវៈ ចម្រុះកម្ពុជាបាន និងកំពុងរៀបចំ និងដាក់ឱ្យប្រើប្រាស់សាកល្បងក្រោមកិច្ចគាំទ្រហិរញ្ញប្បទានឥត សំណងរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) ហើយក៏បានរួមបញ្ចូលគ្នាជាមួយអនុសញ្ញា សហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងអនុសញ្ញាសហប្រជាជាតិប្រយុទ្ធនឹងវាលរហោស្ថានកម្ម។ កម្មវិធីអភិរក្សក្រៅដែនធម្មជាតិបាន និងកំពុងរៀបចំតាមរយៈប្រមូលសំណាកសត្វរុក្ខជាតិ ការបង្កើត សួនរុក្ខឧទ្យាន និងសួនសង្គ្រោះសត្វព្រៃសំដៅប្រមូលថែរក្សាការពារប្រភេទទទួលរងគ្រោះថ្នាក់។

**តារាងទី១៖ សូចនាករសំខាន់ៗ តាមទស្ស័យសម្រាប់ឆ្នាំ២០១៤-២០១៨**

| ល.រ | សូចនាករ | ឯកតា | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន |
| **១. ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** | | | | | | | | | | | | |
| **១.១. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** | | | | | | | | | | | | |
| ១.១.១ | របៀបវារៈជាតិស្តីពីការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា៖ គោលនយោបាយ បទបញ្ញត្តិ គោលការណ៍ណែនាំ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | បរិមាណ | ០ | ០ | ១ | ១ | ២ | ២ | ២ | ២ | ២ | ២ |
| ១.១.២ | សេវាកម្មនិងបច្ចេកវិទ្យាធានាការអភិវឌ្ឍ និងការទទួលយកបច្ចេកវិទ្យានិងសេវាកម្មបៃតង និងប្រកប ដោយការបញ្ចេញកាបូនតិច (អនុវត្តគម្រោងផ្ទេរបច្ចេកវិទ្យា និងការស្រាវជ្រាវ) | ចំនួនគម្រោង | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ | ១ | ១ |

| ល.រ | សូចនាករ | ឯកតា | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន |
| ១.១.៣ | កសាងសមត្ថភាព និងចំណេះដឹង៖ បណ្តុះបណ្តាល ពង្រឹងចំណេះដឹង និងការយល់ដឹងអំពីវិទ្យាសាស្ត្របច្ចេកវិទ្យា និងការសិក្សាស្រាវជ្រាវសំដៅជានាការអភិវឌ្ឍដោយនិរន្តរភាព | ចំនួនបណ្តុះបណ្តាល | ០ | ០ | ០ | ០ | ២ | ២ | ២ | ២ | ៤ | ៣ |
| **១.២. ការអភិវឌ្ឍបៃតង** | | | | | | | | | | | | |
| ១.២.១ | ចំនួនបុគ្គលិកសហគ្រាសធុនតូច និងមធ្យម និងមន្ត្រីរដ្ឋាភិបាលទទួលបានការបណ្តុះបណ្តាលទាក់ទងនឹងនវានុវត្តន៍បៃតង ស្លាកសញ្ញាបរិស្ថាន (អេកូ) និងវិញ្ញាបនបត្រកម្មស្លាកសញ្ញាបរិស្ថាន និងសេដ្ឋកិច្ចបៃតង | នាក់ | ០ | ០ | ០ | ០ | ០ | ០ | ១១០ | ១៤៥ | ១១០ | ១២០ |
| ១.២.២ | ចំនួនក្រុងដែលបានដាក់បញ្ចូល និងបន្សុីផែនការវិនិយោគ | បរិមាណ/ក្រុង | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ |

| ល.រ | សូចនាករ | ឯកតា | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន |
| | មូលដ្ឋានជាមួយនឹងផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភា ២០១៨-២០៣០ សម្រាប់ទីក្រុងរបស់ខ្លួន | | | | | | | | | | | |
| ១.២.៣ | ការសិក្សាស្រាវជ្រាវទាក់ទងនឹងថាមពលកកើតឡើងវិញ (ថាមពលពន្លឺព្រះអាទិត្យ) និង/ឬប្រសិទ្ធផលថាមពលសម្រាប់វិស័យឧស្សាហកម្មបានរៀបចំ | បរិមាណ/លើក | ០ | ០ | ០ | ០ | ០ | ០ | ១ | ១ | ២ | ២ |
| ១.២.៤ | អាទិភាពគោលនយោបាយសម្រាប់ការអភិវឌ្ឍបៃតងបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ | បរិមាណ/វិស័យ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៤ | ៤ |

| ល.រ | សូចនាករ | ឯកតា | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន |
| **២. ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | | | | | | |
| ២.១ | ការចំណាយលើការប្រែប្រួលអាកាសធាតុធៀបនឹង ផ.ស.ស | % | ១,០៧ | ១,៣ | ១,១ | ១,២ | ១,១៣ | ០,៩ | ១,១៦ | | ១,១៨ | |
| ២.២ | បញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ជាតិនិងក្រោមជាតិ | ក្រសួង/ស្ថាប័ន | ១៣ | ៩ | ១៤ | ១៣ | ១៧ | ១៤ | ១៩ | ១៤ | ២១ | ១៤ |
| ២.៣ | ចំនួនឃុំងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុ | ឃុំ | ៦០០ | ៧៩១ | ៥៥០ | N/A | ៥០០ | ៦៩៥ | ៤៥០ | N/A | ៤០០ | N/A |
| ២.៤ | តំណាងកាបូនពីយន្តការអភិវឌ្ឍន៍ស្អាត និងយន្តការដទៃទៀត (REDD+ និងទីផ្សារស្ម័គ្រចិត្ត) | $tCO_2e$ /yr ) | ២.២៨០.៣៧៧ | ២.២២៦.០៦១ | ២.៣៣៤.៦៥០ | ២.២២៦.០៦១ | ២.៣៨៨.៨១៤ | ៧.៣៥០.៩៣៤ | ២.៤៤៣.០៤០ | | ២.៤៩៧.២៧៥ | |
| **៣. ជីវៈចម្រុះ និងជីវសុវត្ថិភាព** | | | | | | | | | | | | |
| ៣.១ | ចំនួនក្រសួង ស្ថាប័ន បានទទួលការផ្សព្វផ្សាយ ពីបញ្ហាជីវៈចម្រុះ | ក្រសួង/ស្ថាប័ន | ១០ | ១៥ | ១៦ | ២០ | ១៦ | ២២ | ១៨ | ២១ | ១៥ | ១៦ |

| ល.រ | សូចនាករ | ឯកតា | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន | ចំណុចដៅ | សម្រេចបាន |
| ៣.២ | ចំនួន នៃការសិក្សាស្រាវជ្រាវ គោលនយោបាយ ច្បាប់ គោលការណ៍ណែនាំ របាយការណ៍ជាតិ និងប្រព័ន្ធព័ត៌មានទាក់ទងនឹងជីវៈចម្រុះ ជីវសុវត្ថិភាពនិងការបែងចែកផលប្រយោជន៍ពីធនធានជីវៈចម្រុះ | ចំនួនស្រាវជ្រាវ/គោលនយោបាយ | ៣ | ៦ | ៥ | ៦ | ៧ | ១០ | ១៥ | ២៩ | ២ | ៣ |
| ៣.៣ | ចំនួនទីតាំង នៃតំបន់អភិរក្សក្រៅដែនធម្មជាតិ | ចំនួនទីតាំង | ០ | ០ | ០ | ០ | ០ | ០ | ២ | ០ | ១ | ១ |
| ៣.៤ | ចំនួននៃទីតាំងអនុវត្តការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី | ចំនួនទីតាំង | ០ | ០ | ០ | ០ | ០ | ០ | ២ | ០ | ១ | ២ |
| ៣.៥ | ចំនួននៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយស្ថាប័នពាក់ព័ន្ធ | ស្ថាប័ន | ១ | ២ | ២ | ២ | ៣ | ៤ | ៣ | ៦ | ២ | ១៥ |
| ៣.៦ | ចំនួនវគ្គកសាងសមត្ថភាព និងផ្សព្វផ្សាយ | ចំនួនវគ្គ | ៣ | ៥ | ៨ | ១២ | ៩ | ១៣ | ៨ | ៧ | ៤ | ៨ |

## II. បញ្ហាប្រឈមនៅក្នុងការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨

### ១. វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការអភិវឌ្ឍបៃតង

#### ១.១. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- នាយកដ្ឋានទើបបង្កើតថ្មីនៅឆ្នាំ២០១៥ នៅមានចំណុចខ្វះខាតច្រើនត្រូវកែលម្អ
- ចំនួនមន្ត្រីតិច សមត្ថភាពជំនាញ និងចំណេះដឹងរបស់មន្ត្រីនៅមានកម្រិត
- ការយល់ដឹង និងការគាំទ្រ កិច្ចសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នៅមានកម្រិត
- សម្ភារៈ មធ្យោបាយ និងធនធានសម្រាប់អនុវត្តការងារនៅមានកម្រិត។

#### ១.២. ការអភិវឌ្ឍបៃតង

- កង្វះខាតចំនួនមន្ត្រី និងសមត្ថភាពរបស់មន្ត្រីក្នុងការរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ គោលការណ៍ណែនាំ និងការងារប្រចាំថ្ងៃ។ មន្ត្រីចំនួន០៦រូប ក្នុងចំណោម ១៤រូបបានបន្តការសិក្សាទាំងក្នុង និងក្រៅប្រទេស
- សេដ្ឋកិច្ចបៃតងមិនទាន់បានបានយល់ដឹងឱ្យបានទូលំទូលាយក្នុងចំណោមក្រសួង ស្ថាប័នរដ្ឋាភិបាល និងសាធារណៈជន
- ថវិកាជាតិនៅមានកម្រិតសម្រាប់ការជំរុញការងារសេដ្ឋកិច្ចបៃតង និងសមត្ថភាពដើម្បីកៀរគរធនធានពីដៃគូនៅមានកម្រិត
- សមត្ថភាពស្ថាប័ននិងមន្ត្រី ក្នុងការតាមដានវាយតម្លៃលើការអនុវត្តគោលការណ៍ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងយន្តការដែលបានដាក់ចេញ នៅមានកំរិត
- នៅមានភាពខ្វះខាតលើសមត្ថភាពលើការស្រាវជ្រាវ វាយតម្លៃ និងការរៀបចំគោលនយោបាយសង្ខេបទាក់ទងនឹងសេដ្ឋកិច្ចបៃតង ដើម្បីផ្តល់ព័ត៌មានពីការសម្រេចចិត្តរបស់អ្នកធ្វើសេចក្តីសម្រេចចិត្តសម្រាប់ជម្រើសសេដ្ឋកិច្ច និងការការពារបរិស្ថាន។

### ២. ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

- សមត្ថភាពនៅមានកម្រិតក្នុងការរៀបចំសំណើគម្រោងដើម្បីទទួលបានហិរញ្ញប្បទានអាកាសធាតុ ដូចជា មូលនិធិបន្សាំ មូលនិធិអាកាសធាតុបៃតង មូលនិធិបរិស្ថានសកល
- ការវាយតម្លៃ និងការសិក្សាតាមវិស័យ និងទូទាំងប្រទេសនៅមានកម្រិត ដូចជា ការវាយតម្លៃភាពងាយរងគ្រោះ សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងការវាយតម្លៃសក្តានុពលកាត់បន្ថយ លទ្ធភាពនិងឥទ្ធិពលនៃបច្ចេកវិទ្យាថ្មីៗសម្រាប់បន្សាំ និងការកាត់បន្ថយដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេច
- សមត្ថភាពស្ថាប័នតាមវិស័យនានាដែលនៅមានកម្រិតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ថវិកាសម្រាប់ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅមានកម្រិត។

## ៣. ការងារជីវៈចម្រុះ និងជីវសុវត្ថិភាព

- ក្នុងនាមរចនាសម្ព័ន្ធស្ថាប័នថ្មី សមត្ថភាព និងធនធានមនុស្សនៅមានកម្រិតក្នុងការរៀបចំគោលការណ៍ ផែនការយុទ្ធសាស្ត្រ យន្តការ នីតិវិធី និងកម្មវិធីលម្អិត
- ការបញ្ជ្រាបជីវៈចម្រុះ និងការអនុវត្តជីវសុវត្ថិភាពក្នុងវិស័យនានាចាប់ពីស្ថាប័នថ្នាក់ជាតិដល់អាជ្ញាធរមូលដ្ឋានទាំងក្នុងក្របខណ្ឌច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងបទប្បញ្ញត្តិនានា ដើម្បីសម្រេចបាននូវគោលដៅដែលបានដាក់ចេញ នៅមានការលំបាក
- សមត្ថភាពស្ថាប័ន នៅមានភាពខ្វះខាត ក្នុងការរៀបចំយន្តការទទួលហិរញ្ញប្បទានជីវៈចម្រុះ ជីវសុវត្ថិភាព និងមូលនិធិអន្តរជាតិពាក់ព័ន្ធជីវៈចម្រុះ
- សមត្ថភាពស្ថាប័ន និងមន្ត្រី នៅមានភាពទន់ខ្សោយ ក្នុងការប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធនឹងជីវៈចម្រុះ និងជីវសុវត្ថិភាព ព្រមទាំងវិភាគប្រើប្រាស់ទិន្នន័យព័ត៌មាន និងចំណេះដឹងទាំងនោះ សម្រាប់គោលដៅផ្សេងៗ
- សមត្ថភាពស្ថាប័ននិងមន្ត្រី ក្នុងការតាមដានវាយតម្លៃលើការអនុវត្តគោលការណ៍ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងយន្តការដែលបានដាក់ចេញ នៅមានកម្រិត
- នៅមានភាពខ្វះខាតលើសមត្ថភាពវាយតម្លៃ និងសិក្សាស្រាវជ្រាវលើធាតុសំខាន់ៗនិងតម្លៃនៃធនធានជីវៈចម្រុះ មុខងារសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនានា
- នៅមានកម្រិត និងប្រឈមទាំងចំណេះដឹង និងឧបករណ៍បរិក្ខាទំនាក់ទំនង ដើម្បីបញ្ជ្រាបជីវៈចម្រុះដល់វិស័យពាក់ព័ន្ធ អ្នកនយោបាយ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងសាធារណជនឱ្យបានគ្រប់គ្រាន់អំពីតួនាទីសំខាន់ៗរបស់ពួកគេ ក្នុងការពារអភិរក្សជីវៈចម្រុះ និងប្រើប្រាស់ឱ្យមាននិរន្តរភាព។

## III. គោលនយោបាយអាទិភាពសម្រាប់ ២០១៩-២០២៣

ដើម្បីអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាកាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៦នៃរដ្ឋសភា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនឹងអនុវត្តយុទ្ធសាស្ត្រអាទិភាពដូចខាងក្រោម៖

## ១. ការអភិវឌ្ឍបៃតង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

### ១.១. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- បន្តអនុវត្តអនុស្សរណៈនៃការយោគយល់ និងកិច្ចព្រមព្រៀងនានាស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាពជាមួយសាជីវកម្មថាមពលបរមាណូរដ្ឋនៃសហព័ន្ធរុស្ស៊ី និងសាជីវកម្មនុយក្លេអ៊ែរជាតិចិននៃសាធារណរដ្ឋប្រជាមានិតចិន ដោយផ្តោតយ៉ាងសំខាន់លើការអភិវឌ្ឍធនធានមនុស្ស ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការប្រើប្រាស់បច្ចេកវិទ្យាថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យ

ឧត្តមប្រយោជន៍សេដ្ឋកិច្ចនិងការអភិវឌ្ឍនៅក្នុងវិស័យអាទិភាពរួមមានវេជ្ជសាស្ត្រ កសិកម្ម ឧស្សាហកម្ម សំណង់ និងបរិស្ថាន។

- បន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយភាគីរុស្ស៊ីក្នុងសាងសង់មជ្ឈមណ្ឌលព័ត៌មាននុយក្លេអ៊ែរ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បន្តចុះសិក្សាស្វែងយល់ ប្រមូល ចងក្រងទិន្នន័យទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាបៃតង
- បន្តរៀបចំសេចក្តីព្រាងក្រមសីលធម៌សម្រាប់ការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាក្នុងបរិបទនៃការអភិវឌ្ឍន៍ដោយចីរភាព កម្មវិធីសិក្សា និងស្រាវជ្រាវថ្នាក់ជាតិ
- លើកកម្ពស់ការយល់ដឹងអំពីវិទ្យាសាស្ត្រ បច្ចេកវិទ្យាបៃតង និងនវានុវត្តន៍
- បន្តសិក្សាស្រាវជ្រាវពីប្រសិទ្ធភាពទោចក្រយានយន្តប្រើថាមពលអគ្គិសនី
- ជំរុញ និងលើកកម្ពស់ការកសាងសមត្ថភាពមន្ត្រីរាជការតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល កិច្ចប្រជុំពាក់ព័ន្ធនៅក្នុង និងក្រៅប្រទេស គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃបច្ចេកវិទ្យាបៃតង និងរបាយការណ៍វាយតម្លៃ និងតម្រូវការបច្ចេកវិទ្យាបៃតងសម្រាប់ប្រទេសកម្ពុជា។

### ១.២. ការអភិវឌ្ឍបៃតង

- បន្តធ្វើសមាហរណកម្មនៃគោលគំនិតស្តីពីទីក្រុងនិរន្តរភាពទៅក្នុងផែនការអភិវឌ្ឍន៍របស់ទីក្រុងដែលបានជ្រើសរើស និងផ្តល់ការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ
- បន្តធ្វើការសិក្សាស្រាវជ្រាវ និងវាយតម្លៃលើផែនការ និងគោលនយោបាយដែលមានស្រាប់របស់ទីក្រុងផ្សេងទៀត ព្រមទាំងសហការជាមួយក្រសួងពាក់ព័ន្ធសំខាន់ៗ និងដៃគូអភិវឌ្ឍក្នុងការកៀរគរកិច្ចគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសទៅដល់ទីក្រុងដែលពាក់ព័ន្ធ
- បន្តធ្វើសមាហរណកម្មនៃគោលគំនិតថាមពលនិរន្តរភាព ទៅក្នុងគោលនយោបាយដែលមានស្រាប់ពាក់ព័ន្ធនឹងថាមពល និងធ្វើការវាយតម្លៃលើផលប៉ះពាល់ដែលមានសារៈប្រយោជន៍ពីថាមពលចម្រុះ
- បន្តលើកកម្ពស់ការអនុវត្តនិងការដំឡើងបន្ទះថាមពលពន្លឺព្រះអាទិត្យនៅតាមអគារសាធារណៈ និងរោងចក្រ ។

## ២. ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

### ក. គោលនយោបាយអាទិភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ

- ប្តេជ្ញាអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា(CCCSP)ឱ្យបានពេញលេញ និងសម្រេចលទ្ធផលនៃការប្តេជ្ញារបស់ NDC និង SDGs
- ធានាគោលនយោបាយ និងយុទ្ធសាស្ត្រថ្មីៗនៃវិស័យដែលពាក់ព័ន្ធនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុនឹងចូលរួមការអភិវឌ្ឍន៍ដែលមានភាពធន់ ការបញ្ចេញកាបូនទាប ត្រូវតែអនុលោមតាមផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា

## ខ. សកម្មភាពអាទិភាព

**យុទ្ធសាស្ត្រ និងផែនការជាតិស្តីពីការប្រែប្រួលអាកាសធាតុ**

- គ្រប់គ្រងនិងផ្សព្វផ្សាយជាសាធារណៈនូវការវាយតម្លៃលម្អិតមួយលើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា ការវិវត្តនៃលិខិតបទដ្ឋានគតិយុត្ត និងវិធានការនានា ការប្តេជ្ញាជាអន្តរជាតិ ព្រមទាំងអាទិភាពនិងតម្រូវការនាពេលអនាគត ដោយសហការជាមួយគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់របស់រដ្ឋាភិបាល និងសង្គមស៊ីវិល
- សម្របសម្រួល ការអនុវត្ត CCCSP និងផែនការស្តីពីការចូលរួមចំណែករបស់រដ្ឋភាគីក្នុងការអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (Nationally Determined Contribution: NDC) ដោយៈ (ក) បង្កើត និងសម្រួលឱ្យមានវិធីសាស្ត្រ និងយន្តការនានាដើម្បីធានាថាក្រសួងដែលរ៉ាប់រងការទទួលខុសត្រូវនិងរដ្ឋបាលនៅថ្នាក់ក្រោមជាតិបានបញ្ជ្រាបគោលនយោបាយ និងសកម្មភាពរបស់ខ្លួនជាមួយ CCCSP និង NDC ។ (ខ) កំណត់ និងលើកកម្ពស់សកម្មភាពនិងលទ្ធផលជាអាទិភាព ការទទួលយកតួនាទីការទទួលខុសត្រូវ និងមធ្យោបាយដើម្បីរក្សាបាននូវមូលនិធិ និងវាយតម្លៃវឌ្ឍនភាពដើម្បីផ្តល់ធាតុចូលសម្រាប់ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាព CCCSP និង NDC។ (គ) ត្រួតពិនិត្យជាទៀងទាត់លើការបំពេញការងារធៀបនឹង CCCSP និង NDC
- ចូលរួមការសន្ទនានៅថ្នាក់តំបន់ និងអន្តរជាតិដែលរួមមានទាំងដំណើរការអាស៊ាន និង UNFCCC ព្រមទាំងរៀបចំ និងដាក់ជូនឯកសារជំហររបស់ជាតិ របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង និងរបាយការណ៍ជាតិនៅក្រោម UNFCCC
- រៀបចំ អនុវត្ត តាមដាន និងផ្សព្វផ្សាយគម្រោងបង្ហាញចំនួន ១០ អំពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលរួមមានទាំងបន្សាំនៃប្រព័ន្ធអេកូឡូស៊ីទីក្រុង យន្តការអភិវឌ្ឍន៍ស្អាត យន្តការឥណទានកាបូនរួមគ្នា និងការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ ព្រមទាំងតួនាទីនៃការអភិរក្ស ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងការពង្រីកសន្និធិកាបូនព្រៃឈើក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (REDD+)។

**ការកសាងសមត្ថភាព ការយល់ដឹង ចំណេះដឹង និងការផ្ទេរបច្ចេកវិទ្យា**

- ពង្រីកការចូលរួម និងកសាងសមត្ថភាពស្ថាប័ន និងបច្ចេកទេសដែលទទួលបន្ទុកការប្រែប្រួលអាកាសធាតុ
- រៀបចំ និងអនុវត្តក្របខ័ណ្ឌជាតិស្តីពីព័ត៌មាន ការយល់ដឹង និងការចូលរួម ព្រមទាំងកម្មវិធីគាំទ្រនានា
- បង្កើតវេទិកាទូលំទូលាយមួយសម្រាប់ៈ (ក) ផលិត ពង្រឹង គ្រប់គ្រង និងបង្កលក្ខណៈងាយស្រួលសម្រាប់ការទទួលបានព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ។ (ខ)បង្កើត និងពង្រឹងយន្តការសម្រាប់កសាងចំណេះដឹង និងលើកកម្ពស់ការស្រាវជ្រាវអំពីការបន្សាំ

នឹងការប្រែប្រួលអាកាសធាតុ និងទម្លាប់អនុវត្ត ព្រមទាំងបច្ចេកវិទ្យាកាត់បន្ថយការប្រែប្រួលអាកាសធាតុ

- វាយតម្លៃជាទៀងទាត់អំពីសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការអនុវត្ត CCCSP បង្កើតកម្មវិធីនានាដើម្បីបំពេញចំណុចខ្វះខាតសំខាន់ៗ និងកៀរគរធនធានសម្រាប់ការអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាព
- វាយតម្លៃ និងជំរុញបច្ចេកវិទ្យាមេត្រីភាពជាមួយអាកាសធាតុ ដល់អ្នកពាក់ព័ន្ធទាំងអស់។

**ហិរញ្ញប្បទានសម្រាប់សកម្មភាពឆ្លើយតបទៅនឹងអាកាសធាតុ៖**

- រៀបចំដំណើរការ និងនីតិវិធីសម្រាប់ស្វែងរក សម្របសម្រួល អង្កេតតាមដាន ផ្ទេរថវិកា និងការធ្វើសវនកម្មហិរញ្ញវត្ថុ
- ធ្វើបច្ចុប្បន្នភាពតម្រូវការ និងយុទ្ធសាស្ត្រសម្រាប់ការទទួលមូលនិធិពីប្រភពក្នុងនិងក្រៅប្រទេសវិធានការអភិវឌ្ឍន៍សមត្ថភាព និងយន្តការ ឬកំណែទម្រង់ស្ថាប័នដែលចាំបាច់សម្រាប់កៀរគរ និងគ្រប់គ្រងហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាពបំផុត
- ដឹកនាំ អនុម័ត ឯកភាព និងសម្របសម្រួលការចាត់ចែងហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលទាក់ទងនឹងការចាត់ចែងហិរញ្ញប្បទាន និងសំណើសុំថវិកាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈ ក.ជ.អ.ច. ដើម្បីធានាការអនុវត្តទៅតាមផែនការ និងយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធ
- រៀបចំកិច្ចពិភាក្សាប្រចាំឆ្នាំអំពីការប្រែប្រួលអាកាសធាតុ ជាមួយវិស័យឯកជនដើម្បីស្វែងរកឱកាសវិនិយោគលើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងសម្រួលឱ្យរដ្ឋាភិបាលទទួលយកវិធានការនិងគោលនយោបាយជាអាទិភាព
- គាំទ្រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងចំពោះការធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងការធ្វើសេចក្តីសម្រេចលើការវិភាជន៍ថវិកា។

## ៣. ការធានាជីវៈចម្រុះ និងជីវសុវត្ថិភាព

- ជំរុញបន្ថែមលើការអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះនិងពិធីសារណាហ្គោយ៉ាស្តីពីការប្រើប្រាស់ និងបែងចែកផលប្រយោជន៍នៃធនធានពន្ធុប្រកបដោយស្មើភាព និងសមធម៌ និងពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព ព្រមទាំងពិធីបន្ថែមណាហ្គោយ៉ា-គូឡាឡាំពួរស្តីពីការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាតទៅនឹងពិធីសារពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព ឱ្យមានប្រសិទ្ធភាព និងតាមគោលដៅ និងផែនការដែលប្រទេសហត្ថលេខីបានឯកភាព តាមរយៈការកសាងសមត្ថភាព ធនធានមនុស្ស ហិរញ្ញវត្ថុ និងដៃគូចូលរួមអនុវត្ត

- ជំរុញគ្រប់មធ្យោបាយ យន្តការ និងវិធីសាស្ត្រនានាដែលមានស្រាប់ និងរៀបចំថ្មីៗ សម្រាប់ការបញ្ច្រាបតម្លៃ មុខងារ និងតួនាទីជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីទៅក្នុងផែនការយុទ្ធសាស្ត្រនានា គោលនយោបាយ និងកម្មវិធីអនុវត្តរបស់វិស័យពាក់ព័ន្ធសំខាន់ៗ រួមមានកសិកម្ម ព្រៃឈើ ជលផល ទេសចរណ៍ ថាមពល រ៉ែ ហេដ្ឋារចនាសម្ព័ន្ធ និងការកែច្នៃ ជាដើម។ វិស័យអប់រំ និងយុត្តិធម៌ ដើរតួនាទីដ៏សំខាន់ និងជាដៃគូក្នុងការអនុវត្តយូរអង្វែងទៅថ្ងៃអនាគត
- រៀបចំក្របខណ្ឌគោលនយោបាយជាតិស្តីពី ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងយន្តការអនុវត្តដោយផ្តោតលើធនធានទឹក និងផលប្រយោជន៍ជីវៈចម្រុះលើវិស័យទេសចរណ៍ ជាជំហានដំបូង និងតាមរយៈការអនុវត្តគម្រោងសាកល្បងនៅប្រភពទឹកសំខាន់ៗ
- រៀបចំយន្តការអនុវត្ត ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័នជាតិ និងដៃគូអនុវត្តលើការងារជីវសុវត្ថិភាពដែលពាក់ព័ន្ធដល់ការផ្តល់វិញ្ញាបនបត្រនាំចេញ នាំចូលសារពាង្គកាយកែច្នៃទាំងក្នុងទម្រង់ ជាចំណីអាហារ ការវេចខ្ចប់ និងសម្រាប់ការកែច្នៃ និងដាក់បញ្ចូលទៅក្នុងធម្មជាតិ ការវាយតម្លៃហានិភ័យមុន និងក្រោយការតាមដាន និងត្រួតពិនិត្យលើការផ្ទេរទុកដាក់ ការដឹកជញ្ជូន ការសាកល្បង ការដោះស្រាយ និងការគ្រប់គ្រងរាល់ហានិភ័យ
- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ រចនាសម្ព័ន្ធគ្រប់គ្រង យន្តការ និងនីតិវិធីរដ្ឋបាលលើការប្រើប្រាស់ និងបែងចែកផលប្រយោជន៍នៃធនធានពន្ធុប្រកបដោយស្មើភាព និងសមធម៌ រវាងអ្នកផ្គត់ផ្គង់ រួមទាំងជនជាតិដើមភាគតិច និងអ្នកប្រើប្រាស់
- រៀបចំ និងកៀរគរបច្ចេកទេស និងហិរញ្ញវត្ថុជាមួយដៃគូជាតិ អន្តរជាតិលើការគ្រប់គ្រង និងការផ្សព្វផ្សាយពីការអភិរក្សក្រៅដែនធម្មជាតិនៃប្រភេទរុក្ខជាតិ និងសត្វ
- បន្តកិច្ចប្រឹងប្រែងដើម្បីអភិវឌ្ឍ និងដាក់ឱ្យអនុវត្តយន្តការ និងនីតិវិធីចាំបាច់នានា លើការប្រមូល បញ្ចូល វិភាគ គ្រប់គ្រង តាមដាន ធ្វើបច្ចុប្បន្នភាព ទិន្នន័យនិងព័ត៌មាន និងរៀបចំជារបាយការណ៍សមស្របទៅតាមគោលដៅ និងកាលៈទេសៈនៃការប្រើប្រាស់ដើម្បីសម្រួលដល់ការប្រើប្រាស់ការទំនាក់ទំនង និងការសម្របសម្រួល រវាងស្ថាប័ននានានៃរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល
- ពង្រឹងសមត្ថភាពស្ថាប័នសិក្សាស្រាវជ្រាវ គ្រប់គ្រងព័ត៌មាននិងចំណេះដឹង តាមដាន និងវាយតម្លៃ អំពីគុណតម្លៃ មុខងារ សេវាកម្ម និងវិវត្តរបស់ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ដោយសម្រួលឱ្យមានការចូលរួមរវាងក្រសួង និងស្ថាប័នជាតិ ថ្នាក់ក្រោមជាតិ គ្រឹះស្ថានអប់រំសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធដទៃទៀត ដែលមានការពាក់ព័ន្ធ និងទទួលផលប្រយោជន៍ពីធនធានជីវៈចម្រុះ
- បន្តកិច្ចប្រឹងប្រែងដោយសហការជាមួយដៃគូជាតិអន្តរជាតិ ដើម្បីកៀរគរ និងស្រូបយកហិរញ្ញវត្ថុជីវៈចម្រុះ ក្នុងបរិមាណកាន់តែច្រើនឡើង សម្រាប់គាំទ្រដល់ការអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី

- រៀបចំឧបករណ៍ បរិក្ខារ សម្ភារ មធ្យោបាយ និងអនុវត្តយុទ្ធសាស្ត្រ និងយន្តការសមស្រប និងចាំបាច់ សំដៅបង្កើនការយល់ដឹង និងការប្រាស្រ័យទាក់ទង ជាមួយសាធារណជន ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ជាតិអន្តរជាតិ ដោយផ្តោតលើផ្នែកខុសៗគ្នា ក្នុងគោលដៅធ្វើឱ្យបណ្តាអ្នកពាក់ព័ន្ធនានាចូលរួមកាន់តែច្រើនថែមទៀតលើកិច្ចការពារ ស្តារ គ្រប់គ្រង និងប្រើប្រាស់ធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី ។

## តារាង២៖ គោលនយោបាយអាទិភាពសម្រាប់ឆ្នាំ២០១៩-២០២៣

| ល.រ | សូចនាករ | ឯកតា | ទិន្នន័យមូលដ្ឋាន ២០១៧ | ២០១៨ គ្រោង | ២០១៩ ព្យាករណ៍ | ២០២០ ព្យាករណ៍ | ២០២១ ព្យាករណ៍ | ២០២២ ព្យាករណ៍ | ២០២៣ ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|---|
| **១. វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការអភិវឌ្ឍបៃតង** | | | | | | | | | |
| **១.១. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** | | | | | | | | | |
| ១.១.១ | របៀបវារៈជាតិស្តីពីការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា៖ ចំនួនគោលនយោបាយ បទបញ្ញត្តិ គោលការណ៍ណែនាំ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | បរិមាណ | ០ | ២ | ៣ | ៣ | ១ | ១ | ១ |
| **១.២. ការអភិវឌ្ឍបៃតង** | | | | | | | | | |
| ១.២.១ | សហគ្រាសឯកជនបានទទួលការបិទស្លាកសញ្ញាបរិស្ថានលើផលិតផល និងសេវាកម្មរបស់ខ្លួន | បរិមាណ | ០ | ០ | ០ | ០ | ២ | ៥ | ៧ |
| ១.២.២ | ចំនួនទីប្រជុំជនក្រុងដែលបានអនុម័ត និងអនុវត្តគម្រោងអាទិភាព និងផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ២០១៨-២០៣០ | បរិមាណ/ក្រុង | ០ | ១ | ៨ | ៨ | ១២ | ១២ | ១២ |
| ១.២.៣ | គោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មស្តីពីអគារបៃតង(សម្រាប់លំនៅដ្ឋាន និងអគារពាណិជ្ជកម្ម) និងស្ថាប័នទទួលបន្ទុកបានបង្កើត និងដាក់ឱ្យប្រើប្រាស់ | បរិមាណ | ០ | ០ | ០ | ១ | ១ | ១ | ១ |
| ១.២.៤ | ភាគរយនៃប្រភពថាមពលកកើតឡើងវិញក្នុងថាមពលចម្រុះជាតិ | បរិមាណ | ០,៣% | ០,៣% | ០,៥% | ១% | ១,៥% | ២% | ៣% |
| **២. ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | | | |
| ២.១ | ភាគរយនៃឃុំងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុ | %(ឃុំ) | ៤២ | ៤០ | ៣៩ | ៣៨ | ៣៧ | ៣៦ | ៣៥ |

| ល.រ | សូចនាករ | ឯកតា | ទិន្នន័យមូលដ្ឋាន ២០១៧ | ២០១៨ គ្រោង | ២០១៩ ព្យាករណ៍ | ២០២០ ព្យាករណ៍ | ២០២១ ព្យាករណ៍ | ២០២២ ព្យាករណ៍ | ២០២៣ ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|---|
| ២,២ | ចំនួនគម្រោងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលបានចុះបញ្ជី (ពី CDM, JCM, NAMA, REDD + និងយន្តការទ្វេភាគីឬ UNFCCC នាពេលអនាគត) នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ | ចំនួនគម្រោង (បូកបង្គរ) | ០ | ១ | ២ | ៤ | ៧ | ១០ | ១៤ |
| ២.៣ | ភាគរយនៃការផ្លាស់ប្តូរការចំណាយលើការប្រែប្រួលអាកាសធាតុធៀបនឹងផលិតផលក្នុងស្រុកសរុប( ផ.ស.ស) | % (ផ.ស.ស) | ១១ | ១២ | ១៤ | ១៥ | ១៥ | ១៥ | ១៦ |
| ២.៤ | កម្រិតនៃស្ថាប័នដែលបានត្រៀមសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុៈការបញ្ជាក់ជាភាគរយ(%) នៃសមត្ថភាពស្ថាប័នដែលបានត្រៀមក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងផ្នែកទាំង៥ | %នៃស្ថាប័ន | ៤៥ | ៤៩ | ៥៣ | ៥៧ | ៦០ | ៦៣ | ៦៥ |
| **៣. ជីវៈចម្រុះ និងជីវសុវត្ថិភាព** | | | | | | | | | |
| ៣.១ | ចំនួនក្រសួង ស្ថាប័ន បានទទួលការបញ្ជ្រាបពីបញ្ហាជីវៈចម្រុះទៅក្នុងផែនការនៃវិស័យពាក់ព័ន្ធ | ចំនួនផែនការ | ២ | ២ | ៣ | ៤ | ៥ | ៦ | ៧ |
| ៣.២ | ចំនួនការសិក្សាស្រាវជ្រាវ គោលនយោបាយ ច្បាប់ គោលការណ៍ណែនាំ របាយការណ៍ជាតិ និងប្រព័ន្ធព័ត៌មាន ទាក់ទងនឹងជីវៈចម្រុះ ជីវសុវត្ថិភាព និងការបែងចែកផលប្រយោជន៍ ពីធនធានជីវៈចម្រុះ | ចំនួនស្រាវជ្រាវ/គោលនយោបាយ | ២ | ២ | ៤ | ៥ | ៦ | ៧ | ៨ |
| ៣.៣ | ចំនួនទីតាំង នៃតំបន់អភិរក្សក្រៅដែនធម្មជាតិ | ចំនួនទីតាំង | ០ | ១ | ៣ | ៥ | ៧ | ៨ | ៨ |
| ៣.៤ | ចំនួននៃទីតាំងអនុវត្តការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី | ចំនួនទីតាំង | ០ | ១ | ២ | ៣ | ៤ | ៦ | ៨ |